| [illegible] | ប៊ុត លីស្រ៊ុន | ប | ០១/១០/១៩៧០ | ខ.៣.១៣ | ក.៣.១៤ |
| ៩៥ | [illegible]ញ សុគន្ធី | ស | ២០/០២/១៩៧៥ | ខ.៣.១៣ | ក.៣.១៤ |
| [illegible] | [illegible] ហៃ | ប | ៣០/០៥/១៩៦៩ | ខ.២.៧ | ក.៣.១៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

| | | | | | |
|---|---|---|---|---|---|
| ៩៧ | ទ៉ា សុធារិទ្ធ | ប | ០៥/០៥/១៩៨១ | ខ.៣.១២ | ក.៣.១៤ |
| ៩៨ | ទ៉ាន់ គីណា | ប | ០១/១២/១៩៧៥ | ខ.៣.១៣ | ក.៣.១៤ |
| ៩៩ | ស៊ាន ម៉ុនថន | ប | ២១/០៨/១៩៧៤ | ខ.៣.១២ | ក.៣.១៤ |
| ១០០ | ស៊ឹម ផាច | ប | ១២/០២/១៩៧០ | ខ.៣.១២ | ក.៣.១៤ |
| ១០១ | សេង ឌី | ប | ០៩/១០/១៩៧៣ | ខ.៣.១២ | ក.៣.១៤ |
| ១០២ | សៀង សេង | ប | ១២/០៣/១៩៧៩ | ខ.៣.១៣ | ក.៣.១៤ |
| ១០៣ | ហាម សុខច័ន្ទ | ស | ០៣/០៩/១៩៧៥ | ឃ.៣.៤ | ក.៣.១៤ |
| ១០៤ | ហេង ម៉េងហ៊ាង | ប | ១២/១០/១៩៧៥ | ខ.៣.១៣ | ក.៣.១៤ |
| ១០៥ | ហាក់ សុខសាន្ត | ប | ០៣/០៧/១៩៧៧ | ខ.៣.១៣ | ក.៣.១៤ |
| ១០៦ | ហ៊ីត សេងហ៊ី | ប | ០៦/០៥/១៩៨៦ | ខ.៣.១៤ | ក.៣.១៤ |
| ១០៧ | ហាម ម៉ាដា | ប | ២២/០១/១៩៧៤ | ខ.៣.១៣ | ក.៣.១៤ |
| ១០៨ | ហ៊ី ម៉ាឡា | ស | ០៥/០៩/១៩៧៧ | គ.៣.១៣ | ក.៣.១៤ |
| ១០៩ | ហាក់ អៀង | ប | ០៨/០៥/១៩៧១ | ខ.៣.៨ | ក.៣.១៤ |
| ១១០ | អែល សុផា | ប | ២៧/១២/១៩៧០ | ខ.២.៨ | ក.៣.១៤ |
| ១១១ | អាន រិទ្ធ | ប | ០៧/០២/១៩៧១ | គ.៣.១១ | ក.៣.១៤ |
| ១១២ | អាង អម្រិន | ប | ០៥/១២/១៩៧២ | ខ.៣.១២ | ក.៣.១៤ |
| ១១៣ | អឹង សុគន្ធា | ស | ០៥/០៩/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |
| ១១៤ | កែ ច័ន្ទសុធារិទ្ធ | ប | ០៤/០៩/១៩៧០ | ខ.៣.១៣ | ក.៣.១៤ |
| ១១៥ | ជៀក សំអុន | ប | ១២/០២/១៩៨៧ | គ.៣.១៤ | ក.៣.១៤ |
| ១១៦ | ម៉ុន រិទ្ធ | ប | ៣០/០៣/១៩៧៥ | ខ.៣.១៣ | ក.៣.១៤ |
| ១១៧ | ចុន រ៉ាស៊ី | ស | ០៩/០១/១៩៨៨ | គ.៣.១៣ | ក.៣.១៤ |
| ១១៨ | នុត ហួន | ប | ១៥/១០/១៩៦៨ | គ.៣.៨ | ក.៣.១៤ |
| ១១៩ | យឹម យ៉េង | ប | ១៥/០៨/១៩៧០ | ខ.៣.១៣ | ក.៣.១៤ |
| ១២០ | សក់ សំអុល | ប | ២៦/០៥/១៩៦៨ | ខ.៣.១៣ | ក.៣.១៤ |
| ១២១ | ហេង សុជាតិ | ប | ០១/០១/១៩៦៩ | ខ.៣.១៣ | ក.៣.១៤ |
| ១២២ | ហួត សុធា | ប | ២៨/០៨/១៩៧៣ | ខ.៣.១២ | ក.៣.១៤ |
| ១២៣ | អែម បញ្ញាឧត្ដម | ប | ២៧/១១/១៩៧០ | ខ.៣.១៣ | ក.៣.១៤ |
| ១២៤ | កែ សារ៉ាន់ | ប | ១០/០៤/១៩៧៤ | ឃ.២.៥ | ក.៣.១៤ |
| ១២៥ | ខាត់ គឿន | ប | ១០/០៦/១៩៧០ | ឃ.២.២ | ក.៣.១៤ |
| ១២៦ | ឃុន ពៅ | ស | ១២/០៤/១៩៦៩ | គ.៣.១២ | ក.៣.១៤ |
| ១២៧ | តូច ផាច | ប | ០៥/០៥/១៩៧៣ | ឃ.២.៥ | ក.៣.១៤ |
| ១២៨ | តែ ច័ន្ទតារារិទ្ធ | ប | ១១/០២/១៩៧២ | ឃ.៣.៥ | ក.៣.១៤ |
| ១២៩ | [illegible] ជា | ប | ១៦/០៣/១៩៦៩ | ឃ.២.៣ | ក.៣.១៤ |
| ១៣០ | ម៉ែន សុវណ្ណដារ៉ា | ប | ១៥/០២/១៩៧១ | ឃ.២.៣ | ក.៣.១៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| | | | | | |
|---|---|---|---|---|---|
| ១៣១ | លាង គីមពុទ្ធា | ស | ២៨/០៣/១៩៧៣ | គ.៣.១៣ | ក.៣.១៤ |
| ១៣២ | ហៀង ឆេងអាន | ប | ០៤/០៤/១៩៧០ | ឃ.២.៥ | ក.៣.១៤ |
| ១៣៣ | ឆន សំឡើង | ប | ១៥/០៣/១៩៧៥ | ខ.៣.១៤ | ក.៣.១៤ |
| ១៣៤ | ម៉េង រដ្ឋ | ប | ១០/១០/១៩៧៤ | ខ.២.៨ | ក.៣.១៤ |
| ១៣៥ | សោ សាម៉ឺឌី | ប | ០៥/១២/១៩៧៤ | ខ.៣.១៣ | ក.៣.១៤ |
| ១៣៦ | ហាក់ មករា | ស | ២២/០៩/១៩៦៨ | ឃ.៣.៨ | ក.៣.១៤ |
| ១៣៧ | អោក ទិបុល | ប | ១២/០២/១៩៧២ | ខ.២.៩ | ក.៣.១៤ |
| ១៣៨ | អៀងណារី | ស | ១០/០១/១៩៧២ | ឃ.៣.៤ | ក.៣.១៤ |
| ១៣៩ | ជា សំណាង | ស | ២៥/១២/១៩៦៩ | គ.៣.១៤ | ក.៣.១៤ |
| ១៤០ | ម៉ៅ ច័ន្ទរតនា | ប | ២២/០១/១៩៧៥ | ខ.៣.១២ | ក.៣.១៤ |
| ១៤១ | សុត វ៉ាត | ប | ១០/០៧/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |
| ១៤២ | ឡេង គន្ធី | ប | ១៥/០៦/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |
| ១៤៣ | ឥន្ទ ស៊ីណេត | ស | ០៩/០៣/១៩៧៦ | ខ.៣.១២ | ក.៣.១៤ |
| ១៤៤ | កង ដារ៉ាឧត្តម | ប | ០៤/១២/១៩៦៩ | ខ.២.១០ | ក.៣.១៤ |
| ១៤៥ | ខៀវ សាខ៊ុន | ប | ២០/១០/១៩៧២ | ខ.៣.១៤ | ក.៣.១៤ |
| ១៤៦ | សំ សោម | ប | ០៦/០៨/១៩៧៩ | ខ.៣.១៤ | ក.៣.១៤ |
| ១៤៧ | ឈាង សុខអួន | ប | ១៥/០១/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |
| ១៤៨ | តែ ដារ៉ា | ប | ០៥/១០/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |
| ១៤៩ | ទី ប៊ុនឡេង | ប | ០៧/០២/១៩៧២ | ខ.៣.១២ | ក.៣.១៤ |
| ១៥០ | ឆុន សុជា | ប | ១៥/០៩/១៩៧៥ | ខ.៣.១៣ | ក.៣.១៤ |
| ១៥១ | ជួរ ជិញ | ប | ១៣/០៤/១៩៨៦ | ខ.៣.១៤ | ក.៣.១៤ |
| ១៥២ | នី បុនិត្យ | ប | ១៥/០១/១៩៧៥ | ខ.៣.១៣ | ក.៣.១៤ |
| ១៥៣ | អ៊ីង ប៊ុនសាង | ប | ៣០/០១/១៩៨២ | ខ.៣.១៣ | ក.៣.១៤ |
| ១៥៤ | អ៊ុំ កែវ | ប | ០៣/០៤/១៩៧៩ | ខ.៣.១៣ | ក.៣.១៤ |
| ១៥៥ | ឃាង ធីរ៉ាផន | ស | ៣០/១០/១៩៧៨ | ឃ.៣.៩ | ក.៣.១៤ |
| ១៥៦ | ហ៊ិន និមិត | ស | ១៣/០៧/១៩៧៧ | គ.៣.១៣ | ក.៣.១៤ |
| ១៥៧ | អ៊ុត សុគុន | ប | ១១/១១/១៩៧៨ | ឃ.៣.៨ | ក.៣.១៤ |
| ១៥៨ | ឆោម ឆវ័ន្ត | ប | ២៥/០១/១៩៨៦ | គ.៣.១៤ | ក.៣.១៤ |
| ១៥៩ | ធន់ សុគឿន | ប | ១៧/១២/១៩៧២ | ខ.៣.១២ | ក.៣.១៤ |
| ១៦០ | ស៊ុំ ឌី | ប | ២០/០៧/១៩៧០ | ខ.២.៧ | ក.៣.១៤ |
| ១៦១ | អ៊ី គង់ | ប | ០១/០៤/១៩៧០ | ខ.៣.១២ | ក.៣.១៤ |
| ១៦២ | ស៊ុក ឫទ្ធីច័ន្ទ | ប | ០១/០១/១៩៨១ | ខ.៣.១៣ | ក.៣.១៤ |
| ១៦៣ | [illegible] ឡេង | ប | ០២/០៥/១៩៦៩ | ខ.៣.១២ | ក.៣.១៤ |
| [illegible] | [illegible] ចាន់ណា | ប | ០៥/០៧/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| | | | | | |
|---|---|---|---|---|---|
| ១៦៥ | គាត កិច្ច | ស | ១៣/០៣/១៩៧២ | ខ.៣.១៣ | ក.៣.១៤ |
| ១៦៦ | ចន្ទ មុនីបោត | ប | ០៥/០៣/១៩៧១ | ខ.៣.១៣ | ក.៣.១៤ |
| ១៦៧ | ស៊ាន ស៊ីវ៉ន | ប | ១៥/០៤/១៩៧០ | ខ.២.៩ | ក.៣.១៤ |
| ១៦៨ | ហុក ប៊ុនហេង | ប | ០៩/១០/១៩៧៩ | ខ.៣.១៣ | ក.៣.១៤ |
| ១៦៩ | ខៀវ ផល្លា | ប | ២៤/០៣/១៩៧២ | ឃ.៣.៣ | ក.៣.១៤ |
| ១៧០ | និត ចាន់ | ប | ១០/១២/១៩៦៩ | គ.៣.១៣ | ក.៣.១៤ |
| ១៧១ | មាស វណ្ណា | ប | ១០/០៥/១៩៧៥ | គ.៣.១៤ | ក.៣.១៤ |
| ១៧២ | ទេង តារៈ | ប | ១៧/០២/១៩៨៦ | ខ.៣.១៤ | ក.៣.១៤ |
| ១៧៣ | ស៊ុំ វាសនា | ប | ០៥/១០/១៩៧២ | ខ.៣.១៤ | ក.៣.១៤ |
| ១៧៤ | សៅ វុទ្ធឿន | ប | ១៦/១២/១៩៧៦ | ខ.៣.១៣ | ក.៣.១៤ |
| ១៧៥ | ហួន សារិន | ប | ០៥/០៤/១៩៧៨ | ខ.៣.១៣ | ក.៣.១៤ |
| ១៧៦ | ហេង រ៉ាត់ធី | ប | ១៨/០៣/១៩៧២ | ខ.៣.១៣ | ក.៣.១៤ |
| ១៧៧ | អៀប ច័ន្ទមុនី | ប | ១៥/០៩/១៩៦៩ | ខ.៣.១៣ | ក.៣.១៤ |
| ១៧៨ | ឈិន ប៉ាវ | ប | ០៦/០៤/១៩៧២ | ខ.៣.១៣ | ក.៣.១៤ |
| ១៧៩ | ប៉ាន់ សារ៉ែន | ប | ០៤/០៥/១៩៦៨ | ខ.៣.១៣ | ក.៣.១៤ |
| ១៨០ | ស៊ីវ រដ្ឋា | ប | ១២/០៨/១៩៦៩ | គ.៣.១៣ | ក.៣.១៤ |
| ១៨១ | ឡុង វុទ្ធី | ប | ១៣/០៦/១៩៦៨ | ខ.៣.១២ | ក.៣.១៤ |
| ១៨២ | ខេង សានិត | ប | ០៦/១០/១៩៨៣ | ខ.៣.១៣ | ក.៣.១៤ |
| ១៨៣ | សែន ស៊ូដ្ឋ | ប | ១២/១០/១៩៧៤ | ខ.៣.១៣ | ក.៣.១៤ |
| ១៨៤ | ថាន់ សារ៉ាវុធ | ប | ០១/១០/១៩៨០ | ខ.៣.១៣ | ក.៣.១៤ |
| ១៨៥ | ម៉ុច ស៊ន់ | ប | ០៤/០៨/១៩៧២ | ខ.២.៩ | ក.៣.១៤ |
| ១៨៦ | សឺង ជូរលី | ប | ២៤/០៣/១៩៧១ | ខ.២.៩ | ក.៣.១៤ |
| ១៨៧ | អ៊ុក សារឿន | ប | ១៣/០៩/១៩៧២ | ខ.៣.១៣ | ក.៣.១៤ |
| ១៨៨ | កែវ ច័ន្ទសោភា | ស | ២៨/០៤/១៩៨៦ | ខ.៣.១០ | ក.៣.១៤ |
| ១៨៩ | គៀត តុងលី | ប | ១៣/០៧/១៩៦៩ | គ.៣.១៣ | ក.៣.១៤ |
| ១៩០ | ឃាង ហេង | ប | ០១/០១/១៩៧០ | ខ.២.៩ | ក.៣.១៤ |
| ១៩១ | ឆាន់ សឿន | ប | ១២/០៥/១៩៨៣ | ខ.៣.១៣ | ក.៣.១៤ |
| ១៩២ | ជឹម ធឿន | ប | ២៩/១០/១៩៨០ | ខ.៣.១៤ | ក.៣.១៤ |
| ១៩៣ | ឈឹម គណិត | ប | ០១/០៦/១៩៨២ | ខ.៣.១៣ | ក.៣.១៤ |
| ១៩៤ | ប្រាង វ៉ែន | ប | ២០/០៧/១៩៧៨ | ខ.៣.១៣ | ក.៣.១៤ |
| ១៩៥ | សយ សុភក្តិ | ប | ១៣/០២/១៩៧៧ | ខ.៣.១៣ | ក.៣.១៤ |
| [illegible] | សុខ សិនិដ្ឋ | ស | ០៥/១០/១៩៨៤ | ខ.៣.១០ | ក.៣.១៤ |
| [illegible]៩៧ | [illegible]ាង ទៀង | ប | ០៩/០៩/១៩៦៩ | គ.៣.១៣ | ក.៣.១៤ |
| [illegible]៨ | [illegible] ប៉ែត | ប | ១៥/០៩/១៩៨១ | ខ.៣.១៣ | ក.៣.១៤ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

| | | | | | |
|---|---|---|---|---|---|
| ១៩៩ | អ៊ុក សាមាណា | ស | ២៥/០៤/១៩៨១ | ខ.៣.១៤ | ក.៣.១៤ |
| ២០០ | ឯក ឧទរ | ប | ០៣/០៨/១៩៧៨ | ខ.៣.១៣ | ក.៣.១៤ |
| ២០១ | ខាំ សាន | ប | ១១/០៨/១៩៦៩ | ខ.៣.១៣ | ក.៣.១៤ |
| ២០២ | ខួន សុធារី | ស | ២៥/០៤/១៩៧៥ | ឃ.៣.១០ | ក.៣.១៤ |
| ២០៣ | គុប ម៉ុនធី | ប | ០៣/០៣/១៩៦៩ | គ.៣.១២ | ក.៣.១៤ |
| ២០៤ | យឹម សំអាង | ប | ១៣/០៩/១៩៧៧ | ខ.៣.៦ | ក.៣.១៤ |
| ២០៥ | រស់ កុយ | ប | ០៣/០៣/១៩៧៥ | ឃ.៣.៧ | ក.៣.១៤ |
| ២០៦ | លីម គឹមលីម | ប | ០៥/០១/១៩៧៣ | ខ.៣.១៣ | ក.៣.១៤ |
| ២០៧ | សំ ម៉ុន្នី | ប | ១០/០៣/១៩៧៧ | ឃ.៣.៣ | ក.៣.១៤ |
| ២០៨ | ស្រួយ ចំរើន | ប | ០៥/០៣/១៩៧០ | ខ.៣.១២ | ក.៣.១៤ |
| ២០៩ | អឿន សុធារី | ស | ០៥/០៦/១៩៨០ | ខ.៣.១២ | ក.៣.១៤ |
| ២១០ | អ៊ុក សុធីឧុធ | ប | ១៥/០៤/១៩៧០ | ខ.៣.១៣ | ក.៣.១៤ |

**មាត្រា ៣.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧ រសរ. ១៣១១. ១១៩៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ ១១៧៦ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម**

**រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣**

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៦

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រោសព្រះរាជទាន

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

១- លោកជំទាវ ធ្វី សុខា
២- លោកជំទាវ ម៉ែន ស្រីពៅ
៣- លោកជំទាវ សុខ ចាសនា
៤- លោកជំទាវ សូ គម ជាសុទ្ធ
៥- លោកជំទាវ សេង គីមហេង
៦- លោកជំទាវ ហេង ឆាន់
៧- លោកជំទាវ នង ច័ន្ទសុខធារី
៨- លោកជំទាវ យឹម រ៉ានី
៩- ឯកឧត្តម កៅ គីមហួន
១០- ឯកឧត្តម ឈី ស៊ុណា
១១- ឯកឧត្តម ហួង ម៉េងហេង
១២- ឯកឧត្តម សុខ លីហួត
១៣- ឧកញ៉ា លឹម ម៉ុនណ្ណា
១៤- ឧកញ៉ា លី ឆៃយូ
១៥- ឧកញ៉ា ប្រាក់ សុចណ្ណ
១៦- ឯកឧត្តម គីម ម៉ាដា
១៧- ឯកឧត្តម ខៀត សំណាង
១៨- ឯកឧត្តម សំ ចិន
១៩- ឯកឧត្តម តុក គីមសាយ

**ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសមៈនារីរត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

១- សម្តេចព្រះវនរ័តកិត្តិបណ្ឌិត ណយ ច្រឹក
២- ព្រះសាក្យវង្ស វ័ន្ត សារឿន
៣- ឧបាសិកា ចឹក ផូ
៤- ឧបាសិកា មួរ ឌួច
៥- លោកជំទាវ អ៊ុច ស្រ៊ី
៦- លោកជំទាវ គី មួយឡេង
៧- លោក ម៉ី ចិន្ត្រា
៨- លោក ឃួត ឈូ

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម ឡុង ដារ៉ា
២- លោកជំទាវ កែវ មុំ
៣- ឧត្តមសេនីយ៍ ម៉ា គិរម្យ
៤- លោក ផេង គីមស្រ៊ុន
៥- លោក លី ឆាយហាក់
៦- លោកស្រី សេរី ចន្ទ

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | ព្រះគ្រូចៅអធិការ | គង់ ចិច្ចិការ | ១៤- | លោកស្រី | ខណ្ណ តារាស្មី |
| ២- | លោកគ្រូសូត្រ | សុខ សុទ្ធ | ១៥- | លោក | ស៊ុំ គី |
| ៣- | លោកគ្រូសូត្រឆ្វេង | ទឹម ហេង | ១៦- | លោក | ជា ឆេង |
| ៤- | លោកគ្រូធម្មាចារ្យ | ហ៊ូ ម៉េត | ១៧- | លោក | ដាង សុចិរៈ |
| ៥- | លោក | យិន អ៊ុម | ១៨- | លោក | ដាង សុគីរុណ |
| ៦- | លោកជំទាវ | ឈឹម ម៉ៅចារ៉ូ | ១៩- | លោក | ស៊ី ម៉ារ៉ែត |
| ៧- | លោកជំទាវ | ក្វាន សំថៃ | ២០- | លោក | សន ពិសី |
| ៨- | លោកស្រី | អ៊ិន សុគន្ធ | ២១- | លោក | សំ សេដ្ឋា |
| ៩- | លោក | សោម សារ៉ាត់ | ២២- | លោក | សុខ អុទ្ទុធី |
| ១០- | លោក | ជា សុខាណារិន | ២៣- | លោកស្រី | ទឹម តារុណ |
| ១១- | លោកស្រី | ហេង មុំ | ២៤- | លោកស្រី | បូរ សម្បត្តិ |
| ១២- | លោកស្រី | គួច ច័ន្ទនាង | ២៥- | លោកស្រី | ថោង សូឈីម |
| ១៣- | លោកស្រី | និន រ៉ាត់ | | | |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នរស. ១៣១១. ១២០០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ ១១៧៥ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៨៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **រឿង រដ្ឋា** ជាទីប្រឹក្សាក្រសួងមុខងារសាធារណៈ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ករ.១៣១១.១២០១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១១៦៥ ស.ណ
**សំណៅដែលមានតម្លៃស្មើការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៧៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.** តែងតាំងឯកឧត្តម **ស៊ិន សឿន** ជាទីប្រឹក្សាអមក្រសួងផែនការ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២.** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ: ១១៧១ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់ឋានៈជា សាស្ត្រាចារ្យ ក្នុងវិស័យការពារជាតិ ដល់នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៖

| | | | |
|---|---|---|---|
| ១-នាយឧត្តមសេនីយ៍ | **នាង** | **ផាត** | អត្តលេខ ០០០០៨០ |
| ២-ឧត្តមសេនីយ៍ឯក | **អ៊ុង** | **ស៊ាន** | អត្តលេខ ០០០១១៣ |
| ៣-ឧត្តមសេនីយ៍ឯក | **មាស** | **សំអុល** | អត្តលេខ ០០០២១១ |
| ៤-ឧត្តមសេនីយ៍ឯក | **ម៉ម** | **សុផាត** | អត្តលេខ ០០០១៦៤ |
| ៥-ឧត្តមសេនីយ៍ឯក | **ណុប** | **រតនា** | អត្តលេខ ០០១៨៨១ |
| ៦-ឧត្តមសេនីយ៍ទោ | **អួន** | **សារឿន** | អត្តលេខ ០០០៧១៨ |
| ៧-ឧត្តមសេនីយ៍ត្រី | **នឹម** | **បាឡែន** | អត្តលេខ ០២៥៦៨២ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤. ១៣១១. ២០១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣*

លេខៈ ១៦៦៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/១១១៣/៧៧៩០

# ព្រះរាជក្រឹត្យ

## ស្តីពីការកែសម្រួលព្រះរាជក្រឹត្យ

## លេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧

## ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២

## ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកក/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមុខងារ ភារកិច្ច រចនាសម្ព័ន្ធ និង កិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ដែលត្រូវបានកែសម្រួលដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ដែលមានខ្លឹមសារដូចខាងក្រោម ៖

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

**«ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ»** ហៅកាត់ថា **«ឧបស»** គឺជាស្ថាប័នខួរក្បាលខាងគោលនយោបាយអភិវឌ្ឍសង្គម- សេដ្ឋកិច្ច សម្រាប់ប្រមុខរាជរដ្ឋាភិបាល នៅអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ជំពូកទី ២
### សមាសភាព និង រចនាសម្ព័ន្ធចាត់តាំង នៃ ឧបស

**មាត្រា ២.-**

**ឧបស** មានសមាសភាព និង រចនាសម្ព័ន្ធចាត់តាំង ដូចខាងក្រោម ៖

- **ឧបស** មានសមាជិកយ៉ាងតិចប្រាំបួនរូប ដែលត្រូវមានគុណសម្បត្តិ ចំណេះវិជ្ជា និងបទពិសោធន៍ការងារក្នុងវិស័យណាមួយនៃមុខជំនាញសំខាន់ៗ ដូចជា សេដ្ឋកិច្ច ហិរញ្ញវត្ថុ នីតិសាស្ត្រ រដ្ឋបាលសាធារណៈ ពាណិជ្ជកម្ម កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ឧស្សាហកម្ម ឬ វិស្វកម្ម
- **ឧបស** ត្រូវបានដឹកនាំ និង គ្រប់គ្រង ដោយប្រធាន និង មានអនុប្រធានមួយចំនួនជាជំនួយការតាមសេចក្តីត្រូវការចាំបាច់
- ប្រធាន និង អនុប្រធាន **ឧបស** អាចមានជំនួយការអមមួយចំនួនតាមតម្រូវការចាំបាច់ជាក់ស្តែង
- សមាជិក **ឧបស** នីមួយៗ អាចមានជំនួយការអមមិនលើសពីពីររូប ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះដឹងយ៉ាងតិចចាប់ពីថ្នាក់បរិញ្ញាបត្រឡើង
- ប្រធាន **ឧបស** មានឋានៈស្មើទេសរដ្ឋមន្ត្រី
- អនុប្រធាន **ឧបស** មានឋានៈស្មើរដ្ឋមន្ត្រី
- សមាជិក **ឧបស** អាចមានឋានៈស្មើរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ
- ជំនួយការអមប្រធាន អនុប្រធាន និងសមាជិក **ឧបស** អាចមានឋានៈស្មើ អគ្គនាយក ឬ អគ្គនាយករង ឬ ប្រធាន



នាយកដ្ឋាន ។

**មាត្រា ៣.-**

**គបស** មានប្រធានកិត្តិយសមួយរូប ដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជន ដែលមានគុណសម្បត្តិក្នុងការបម្រើប្រទេសជាតិ មានបទពិសោធន៍ខ្ពស់ និងមានការទទួលស្គាល់ក្នុងមជ្ឈដ្ឋានជាតិ និងនៅលើឆាកអន្តរជាតិ ។ ប្រធានកិត្តិយស **គបស** មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ឬ ឧបនាយករដ្ឋមន្ត្រី ។

**មាត្រា ៤.-**

**គបស** អាចមានទីប្រឹក្សា ឬ ទីប្រឹក្សាកិត្តិយសមួយចំនួន ដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជនជាតិខ្មែរ ឬ បរទេស ដែលមានគុណសម្បត្តិក្នុងការបម្រើផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា មានបទពិសោធន៍ខ្ពស់ និងមានការទទួលស្គាល់នៅក្នុងមជ្ឈដ្ឋានជាតិ និងនៅលើឆាកអន្តរជាតិ ។

**គបស** អាចមានអ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនដែលមានសមត្ថភាពជំនាញ និងបទពិសោធន៍ខ្ពស់ ដើម្បីជួយបម្រើការងារជាទីប្រឹក្សាបច្ចេកទេស ។

**មាត្រា ៥.-**

**គបស** មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ សម្រាប់គាំទ្រកិច្ចដំណើរការការងាររបស់ខ្លួន ។

អគ្គលេខាធិការដ្ឋាន **គបស** ជាស្ថាប័នប្រតិបត្តិ ដែលដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ដែលអាចមានឋានៈស្មើអនុរដ្ឋលេខាធិការ ឬ អគ្គនាយក ។

មន្ត្រីបម្រើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន **គបស** គឺជាមន្ត្រីរាជការ នៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

ក្នុងករណីចាំបាច់ **គបស** អាចមានអ្នកជំនាញ ឬ បុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារនៅក្នុងអគ្គលេខាធិការដ្ឋានរបស់ខ្លួន ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គបស** ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៣
## មុខងារ និង ភារកិច្ច

**មាត្រា ៦.-**

**គបស** មានមុខងារ និង ភារកិច្ច ដូចតទៅ ៖

- ពិនិត្យ និងរៀបចំឯកសារវិភាគ ស្រាវជ្រាវ និងសុន្ទរកថាសំខាន់ៗ ព្រមទាំងលើកឡើងនូវគំនិតផ្តួចផ្តើមទាំងឡាយ ដែលមានចរិតជាចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់ និងអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ជូនប្រមុខរាជរដ្ឋាភិបាល
- រៀបចំអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល សំដៅធានាឱ្យបាននូវគុណភាព និងសង្គតិភាពនៃគោលនយោបាយអភិវឌ្ឍសង្គម- សេដ្ឋកិច្ច នៅក្នុង និងរវាងវិស័យនានា និង ផ្តល់យោបល់ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ចេញនូវទិសដៅច្បាស់លាស់ សម្រាប់អនុវត្តឱ្យបានរលូននូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល

- ស្នើឡើងនូវវិធានការជាក់ស្តែងនានា ក្នុងទិសដៅកែលំអការគ្រប់គ្រងសង្គម- សេដ្ឋកិច្ច និង ពង្រឹងអភិបាលកិច្ច ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និងបូកសរុបរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ព្រមទាំងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីតម្រង់ទិស និងបង្កើនល្បឿនអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីទាំងនោះ
- ធ្វើជាសេនាធិការជូនប្រមុខរាជរដ្ឋាភិបាល ក្នុងការតាមដាន និងបូកសរុបការអនុវត្តការងារកែទម្រង់ និងគំនិតផ្តួចផ្តើមនានា ក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ចេញដោយផ្ទាល់
- បូកសរុប និងធ្វើរបាយការណ៍សង្ខេបជូនប្រមុខរាជរដ្ឋាភិបាលជ្រាបអំពីស្ថានការណ៍សេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ ហើយផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដំណើរការនយោបាយសេដ្ឋកិច្ចជាតិ ឱ្យស្របទៅតាមនិន្នាការវិវត្តនៃសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចអន្តរជាតិ
- បំពេញការងារផ្សេងទៀត តាមការបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ៤

## កិច្ចដំណើរការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**មាត្រា ៧.-**

**ឧបស** បើកការប្រជុំរបស់ខ្លួនទៅតាមតម្រូវការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន ឬ តាមសេចក្តីបង្គាប់របស់ប្រមុខរាជរដ្ឋាភិបាល ។

**ឧបស** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ខ្លួន នៅក្នុងការបំពេញការងារ ។

**មាត្រា ៨.-**

ដើម្បីអាចបំពេញការងាររបស់ខ្លួន ដូចមានចែកនៅក្នុងមាត្រា ៦ ខាងលើ ជូនប្រមុខរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ **ឧបស** ត្រូវមានតំណាងចូលរួមតាមដាន និង ផ្តល់យោបល់ នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រី និង អង្គប្រជុំអន្តរក្រសួង- ស្ថាប័នផ្សេងៗ ក្នុងទិសដៅធានាសង្គតិភាព និង ភាពរលូន ក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការកែទម្រង់នានារបស់រាជរដ្ឋាភិបាល ។

គ្រប់ក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល មានភារកិច្ចផ្តល់ឯកសារ ព័ត៌មាន និង កិច្ចសហការចាំបាច់នានាជូនដល់ **ឧបស** ។

**ឧបស** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង- ស្ថាប័ននានានៃរាជរដ្ឋាភិបាល ឬ ឥស្សរជន ដែលមានបទពិសោធន៍ និង សមត្ថភាពខ្ពស់ ដើម្បីមកចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

## ជំពូកទី ៥

## ប្រភពធនធាន

**មាត្រា ៩.-**

**គបស** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានសិទ្ធិទទួល និង គ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និង ពីប្រភពផ្សេងទៀត សម្រាប់ចំណាយលើការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និង សម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និង ការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ក្នុងគោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និង ភារកិច្ចរបស់ខ្លួន ។

**មាត្រា ៧ី.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ចី.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី **១៥** ខែ **វិច្ឆិកា** ឆ្នាំ ២០១៣

នស/រកត.១៣១១.១២០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

លេខៈ ១១៦០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដាឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៥ នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ជូអេ ហ្គូតូ** (CHYUEI GOTO) ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ**។

**មាត្រា ២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១៣១១.១២០៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣*

លេខ:១១៥៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១១៩៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៥ នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង:

ក- ទីប្រឹក្សា

១- ឯកឧត្តម **ទ៉ាន់ សេងលី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

២- ឯកឧត្តម **ឈី សុខា** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៣- ឯកឧត្តម **ហេង ដាវ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

៤- ឯកឧត្តម **ហុង ម៉ុងហេង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

៥- ឯកឧត្តម **សន សុផល** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៦- ឯកឧត្តម **អ៊ុង សួនស្មើ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

៧- ឯកឧត្តម **ឡាច លៀង** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ខ- ជំនួយការ

១- ឯកឧត្តម **ស៊ឹម សារិន** ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អគ្គនាយក** ។

២- ឯកឧត្តម **គុប សារឿន** ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។

៣- ឯកឧត្តម **យ៉ុទ ខេមរា** ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា ២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស.រកត.១១១៣.១២០៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១១២៤ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ប្តូរប្រភេទក្របខ័ណ្ឌស្របតាមឧបនិស្ស័យមុខតំណែង ជូនលោក **ខូន យន** ពីនាយក្រមការ ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ទៅអនុមន្ត្រី ថ្នាក់លេខ ៨ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស. ១៣១១.១២០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១១៩២ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្នខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៦៦ ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងទីប្រឹក្សាក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ) ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | គាត រស្មី | ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២. | ឯកឧត្តម | ម៉ែន សុំគៃណ្ឌីឌី | ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣. | ឯកឧត្តម | ម៉ៅ សេខ | ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៤. | ឯកឧត្តម | ឯក ផា | ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ រដ្ឋលេខាធិការ |
| [illegible] | ឯកឧត្តម | យ៉ាន់ ទ៉ាន់យ៉ង់ | ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៦. ឯកឧត្តម **តូ** **ឆានធី** ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៧. លោកជំទាវ **ឡៅ** **សារទេវី** ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៨. ឯកឧត្តម **ជា** **វិចិត្រ** ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៩. ឯកឧត្តម **ស៊ឹម** **សុផុន** ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

១០. លោកជំទាវ **គង់** **វណ្ណា** ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អគ្គនាយក

១១. ឯកឧត្តម **គីម** **តែយ៉ុង** (H.E. Kim Tae Yeon) ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្សរ៍

១២. ឯកឧត្តម **ស៊ីន** **ជុងម៉ាន់** (H.E. Shin Jong Man) ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្សរ៍

១៣. ឯកឧត្តម **កៅ** **មុយលីម** ទីប្រឹក្សា ក.ក.ជ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្សរ៍

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.១៣១១.១២០៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ:១១៩៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

**រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៣**

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៥

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងមន្ត្រីរាជការចំនួន ០៤ រូប ជាទីប្រឹក្សាអម និងជំនួយការក្រសួងពាណិជ្ជកម្ម ៖

១. ឯកឧត្ដម បុន សង់ ជាទីប្រឹក្សាអមក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ
២. ឯកឧត្ដម អ៊ឹ ភូរី ជាជំនួយការក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អគ្គនាយក
៣. ឯកឧត្ដម ជួប សឿន ជាជំនួយការក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អគ្គនាយក
៤. ឯកឧត្ដម ជួង ពេជ្រ ជាជំនួយការក្រសួងពាណិជ្ជកម្ម មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២:** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

ចរស.១៣១១.១២០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខ:១១៩៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម សេរី ជំនះ ជាទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស. ១៣១១. ១៤១០

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខៈ១២៤៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោកជំទាវ តាន់ គឹមហ៊ៀត ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋលេខាធិការ ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ទស. ១៣១១. ១២១១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១៣

លេខ: ១១៩៧ស.ណ
**សំណៅដែលមានចម្លងជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សូយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ហួត សុគុណ ជាទីប្រឹក្សាក្រសួងសុខាភិបាល មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តតាមព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ រល. ១៣១១. ១២១២

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣

លេខៈ១២៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១១១៣/១១៨៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង៖

១- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទេសាភិបាល ប្រចាំធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី

២- ឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទេសាភិបាលជំនួស ប្រចាំធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣*

លេខៈ ១១៩៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៥.៦៩២ ហិកតា នៅស្រុកគូលែន ខេត្តព្រះវិហារ ក្នុងនោះ កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធី.អី.ភី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេមីណិន អ៊ីលីត (ខេមបូឌា) ខូអិលធីឌី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វេភី ម៉ាឡេស៊ី (ខេមបូឌា) ផ្លេនថេសិន ខូ អិលធីឌី និងកាត់ចេញពីដីដែលគ្រោងផ្តល់សម្បទានសង្គមកិច្ច សម្រាប់អតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.៥៥១ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៧៦/២០១៣ គ.គ្រ.ដ.រ.ខ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៥.៦៩២ ហិកតា ក្នុងនោះ (១) ទំហំ ២.១១៧,៥០ ហិកតា កាត់ចេញពីដីព្រៃសម្បទានរបស់ក្រុមហ៊ុន ធី.ភី.ភី និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (២) ទំហំ ១.៤០០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនអេមីណិន អ៊ីលីត (ខេមបូឌា) ខូអិលធីឌី (៣) ទំហំ ៣៤២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វេភី ម៉ាឡេស៊ី (ខេមបូឌា) ផ្លេនថេសិន ខូ អិលធីឌី និង (៤) ទំហំ ១,៨៣២.៥០ ហិកតា កាត់ចេញពីដីដែលគ្រោងផ្តល់សម្បទានសង្គមកិច្ចសម្រាប់អតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិស្រយ៉ង់ជើង ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២:** ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ១.៥៥១ គ្រួសារ នៅភូមិស្រយ៉ង់ជើង ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

